ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ៤៩៧-សណ-១៧ អអក

ភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់
# លោក សេង គ្រី សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោក សេង គ្រី ដើម្បីអនុញ្ញាតឲ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយដែលមានស្រាប់ តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនលោក សេង គ្រី ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ……………
……………………………………………………………………………………សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក សេង គ្រី អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

បណ្ឌិត.ទី នរិន្ទ

សេចក្ដីព្រាង

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្ដីសម្រេចកែសម្រួលលើកទី២
## លើឯកសារអាជ្ញាបណ្ណលេខ ២៩២ ឯអ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ សម្រាប់លោក សេង គ្រី ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

## សម្រាប់ការពង្រីកតំបន់ចែកចាយ

**DECISION ON THE SECOND REVISION**

OF THE LICENSE DOCUMENT No.292 LD DATED JUNE 15, 2010
OF MR. SENG KRY FOR PROVIDING ELECTRIC POWER SERVICE
AT SOME PART OF STUNG TRANG DISTRICT,
KAMPONG CHAM PROVINCE

**FOR EXTENDING DISTRIBUTION AREA**

ថ្ងៃទី....... ខែ....... ឆ្នាំ២០១៧

......., 2017

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ -១៧-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី២ លើឯកសារអាជ្ញាបណ្ណលេខ ២៩២ ឯអ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ សម្រាប់លោក សេង គ្រី

# DECISION ON THE SECOND REVISION OF THE LICENSE DOCUMENT No.292 LD DATED JUNE 15, 2010 FOR MR. SENG KRY

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 34 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ២៩២ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យលោក សេង គ្រី នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០

-Refer to the License Document No.292 LD issued by Electricity Authority of Cambodia to Mr. SENG KRY on June 15, 2010.

-យោងលិខិតស្នើសុំរបស់លោក សេង គ្រី ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

- Refer to the requested letter of Mr. Seng Kry, dated June 22, 2017

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០១៧ ដល់ថ្ងៃទី... ខែ... ឆ្នាំ២០១៧

- In accordance with the consultation with concerned parties and public, made from .... ..., 2017 to ......., 2017

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ចុះថ្ងៃទី ខែ ឆ្នាំ២០១៧

- In accordance with the decision of Electricity Authority of Cambodia's Session No., dated, 2017